# កំណាព្យ៖ ជាតជាគតមនុស្ស

*និពន្ធដោយ  ឃុន អាឡិច (២០០៥)*

បើនិយាយត្រូវធ្វើ　　កុំអើពើឥតប្រយោជន៍
បើចេះតែប៉ប៉ោច　　នាំឲ្យហោចហែងចិន្តា។

**មិនធ្វើកុំទិតៀន　　នាំកើតមានផលជម្លោះ**
**បើមាត់ចេះតែរស់　　នោះជម្លោះនឹងកើតមាន។**

មិនធ្វើក៏មិនថ្វី　　នាំប្រពៃសុខគេឯង
ចិត្តស្ងប់ល្អក្រៃលែង　　នាំឲ្យគេងស្ងប់ចិន្តា។

**កុំចេះតែសន្ទនា　　នាំគ្គីគ្នាប្រាជ្ញឥតការ**
**គិតសិនចាំវាចារ　　នោះទើបថាជាបណ្ឌិត។**

នៅស្ងៀមប្រសើរជាង　　មិនលំអៀងទៅខាងណា
ត្រូវយល់ពីហេតុការណ៍　　ពិចារណារកហេតុផល។

**បើបានជានិយាយ　　កុំមាក់ងាយខ្លួនអាត្មា**
**បុគ្គលសាមញ្ញណា　　ត្រូវគិតថាគេក៏មនុស្ស។**

ត្រូវអប់រំចិត្តចរិយា　　ពីព្រោះថាវាជួយយើង
នៅគ្រាក្តៅមានភ្លើង　　វាជួយយើងរំងាប់ចិត្ត។

**ធ្វើចិត្តឲ្យត្រជាក់　　កុំជំពាក់រឿងសង្ខារ**
**ពិសោធន៍ដឹងហើយថា　　ធម៌សង្ខារមិនឋិតថេរ។**

កើតជាមនុស្សទៅហើយ　　គ្មានអ្វីឡើយប្រសើរជាង
ត្រូវរកផ្លូវនិព្វាន　　ព្រោះថាគ្មានអ្វីប្រៀបផ្ទឹម។

**ជាតិមនុស្ស និងទេវតា　　ទោះយ៉ាងណានៅមិនទៀង**
**គ្មានអ្វីប្រសើរជាង　　ដូចនិព្វានរលត់សូន្យ៕**